សំរេច

មាត្រា ១ ._ ត្រូវបានបង្កើតស្រុកត្រពាំងប្រាសាទ ដោយកាត់យកភូមិសាស្ត្រមួយចំណែកពីស្រុកអន្លង់វែង ។

មាត្រា ២ ._ ស្រុកត្រពាំងប្រាសាទ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង រដ្ឋបាលរបស់ខេត្តឧត្តរមានជ័យ ។

មាត្រា ៣ ._ ស្រុកត្រពាំងប្រាសាទ ត្រូវបង្កើត ឃុំចំនួន ០៦ គឺ ឃុំ ត្រពាំងប្រាសាទ ឃុំបាក់អន្លូង ឃុំអូរស្វាយ ឃុំព្រះប្រឡាយ ឃុំផ្អាវ នឹង ឃុំ ទំនប់ដាច់ ។

មាត្រា ៤ ._ ស្រុកត្រពាំងប្រាសាទ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់ នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៏
- ខាងកើតទល់ នឹងខេត្តព្រះវិហារ
- ខាងត្បូងទល់ នឹងស្រុកស្វាយលើ ខេត្តសៀមរាប
- ខាងលិចទល់ នឹងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

មាត្រា ៥ ._ ទីតាំងសាលាស្រុកត្រពាំងប្រាសាទ ស្ថិតក្នុងឃុំត្រពាំងប្រាសាទ ។

មាត្រា ៦ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៤ អនក្រ.បក

## ស្តីពីការ បង្កើតនិទាឃរដូវវប្បធម៌ជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សំរេច

មាត្រា ១ ._ កំណត់យកថ្ងៃ០៣ ខែមេសា រៀងរាល់ឆ្នាំ ជាថ្ងៃបើក "និទានបុរាណ" របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ធ្វើជា " និទានបុរាណជាតិ " នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ ._ ក្នុងលក្ខណៈត្រៀមប្រារព្ធ " និទានបុរាណជាតិ " ០៣ មេសា គ្រប់ក្រសួងស្ថាប័នរដ្ឋ អាជ្ញាធរ គ្រប់ខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវបំផុសអប់រំមន្ត្រីរាជការ នគរបាល កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់ស្រទាប់អោយយល់ដឹង អំពីនយោបាយវប្បធម៌ជាតិ អត្តសញ្ញាណជាតិ ស្មារតីការពារវប្បធម៌សិល្បៈ បេតិកភណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ និងស្មារតីគោរពច្បាប់ និង បទបញ្ញត្តិនានា ស្តីពីការគ្រប់គ្រង និង ការពារសម្បត្តិវប្បធម៌ជាតិ និងបរិស្ថានវប្បធម៌ជាតិ ។

មាត្រា ៣ ._ បង្កើតគណៈកម្មការអន្តរក្រសួងមួយសំរាប់រៀបចំប្រារព្ធ "និទានបុរាណជាតិ " ០៣ មេសា រៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៩៩ នេះតទៅ ដើម្បី បង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការស្តារវប្បធម៌ជាតិ និងលើកកំពស់ ការយល់ដឹង អំពីអត្ថប្រយោជន៍ នៃវិស័យវប្បធម៌និង វិចិត្រសិល្បៈ សំដៅរួមចំណែកស្តារ និង អភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចជាតិ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

សមាសភាពនៃគណៈកម្មការនេះមាន ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាប្រធាន |
| ២- រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣- អនុប្រធាន គណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ | ជាអនុប្រធាន |
| ៤- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥- រដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា | ជាសមាជិក |
| ៦- រដ្ឋលេខាធិការក្រសួង ពត៌មាន | ជាសមាជិក |
| ៧- រដ្ឋលេខាធិការក្រសួង មហាផ្ទៃ | ជាសមាជិក |
| ៨- រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៩- រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ជាសមាជិក |
| ១០- រដ្ឋលេខាធិកា ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១១- រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ១២- រដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | ជាសមាជិក |
| ១៣- រដ្ឋលេខាធិការ ក្រសួងកិច្ចនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ១៤- អភិបាលរង រាជធានីភ្នំពេញ និងអភិបាលរងខេត្ត-ក្រុងទូទាំងប្រទេស | ជាសមាជិក |

មាត្រា ៤ ._ គណៈកម្មការនេះមានភារកិច្ច ៖

- ធ្វើសារាចរណែនាំ ស្តីពីការរៀបចំ ប្រារព្ធពិធី " និទានបុរាណជាតិ " ០៣ មេសា ។
- រៀបចំប្រធានបទ ខ្លឹមសារ រូបភាព បំរើអោយ " និទានបុរាណជាតិ " ក្នុងឆ្នាំនីមួយៗ ។
- បង្កើតអនុគណៈកម្មការមួយចំនួន បើមានការចាំបាច់ ។

- បំផុស និងអំពាវនាវគ្រប់មជ្ឈមដ្ឋាន និងសប្បុរសជនដើម្បីជួយឧបត្ថម្ភគាំទ្រ "និទានឬធម៌ជាតិ"

មាត្រា ៥ .- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា ៦ .- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជួយសម្របសម្រួលថវិកាជូនគណៈកម្មការនេះតាមតម្រូវការជាក់ស្តែង ។

មាត្រា ៧ .- រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ គណៈកម្មការរៀបចំបុណ្យជាតិ អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ២៥ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវាមហោស្រព

## អង្គរ ឆ្នាំ ១៩៩៩-២០០០

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃកាលានុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី២០

## សម្រេច

មាត្រា ១ .- បង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មួយ ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន